ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សូមគោរពជូន**
**លោកជំទាវឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

*លោកជំទាវជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ យើងខ្ញុំមានសេចក្តីក្រៀមក្រំជាអនេកប្បការ ចំពោះការទទួលមរណភាពរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉េង ង៉ាត់** សមាជិកព្រឹទ្ធសភា និងជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈនៃព្រឹទ្ធសភា កាលពីវេលាម៉ោង ០១:៣៥នាទី ទៀបភ្លឺ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ក្នុងជន្មាយុ ៦៦ឆ្នាំ ដោយរោគាពាធ ។

ក្នុងក្តីវិយោគដ៏សែនក្រៀមក្រំស្មើររកទីបំផុតគ្មាននេះ យើងខ្ញុំសូមចូលរួមសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉េង ង៉ាត់** ដែលជាសមាជិកព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម ក្នុងការបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋគួរជាទីគោរពស្រឡាញ់ និងចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការអភិវឌ្ឍន៍ស្ថាប័នព្រឹទ្ធសភា ក្នុងទឹកចិត្តស្នេហាជាតិដ៏បរិសុទ្ធ ។ ជាមួយគ្នានេះ យើងខ្ញុំសូមចូលរួមរំលែកទុក្ខ ដោយសេចក្តីសោកសង្រេងយ៉ាងក្រៃលែង និងសោកស្តាយជាទីបំផុតជាមួយលោកជំទាវ និងក្រុមគ្រួសារ ដែលបានបាត់បង់នូវឧត្តមស្វាមី បិតា ជីតា ជាទីគោរពស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ និង ទឹកចិត្តសណ្តោសប្រណីដ៏ថ្លៃថ្លា ។

យើងខ្ញុំទាំងអស់គ្នា សូមបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉េង ង៉ាត់** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកជំទាវឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**